# ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ

# ឯកសារណែនាំអនុវត្តន៍

# ការវិភាគប្រព័ន្ធកសិកម្ម-បរិស្ថានឃុំ (CAEA) បានកែលំអថ្មី

## ដើម្បីគាំទ្រការធ្វើផែនការអភិវឌ្ឍន៍ឃុំ-សង្កាត់

## សម្រាប់

## កម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ

**ខែមេសា ២០១៦**

# បញ្ជីពាក្យកាត់

| | |
|---|---|
| AE | ប្រព័ន្ធក្សេត្រ-បរិស្ថាន |
| CAEA | ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ |
| CAEA-MIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ |
| CC | ក្រុមប្រឹក្សាឃុំ សង្កាត់ |
| CDP | ផែនការអភិវឌ្ឍន៍ឃុំសង្កាត់ |
| CIP | កម្មវិធីវិនិយោគឃុំ សង្កាត់ |
| CLUP | ផែនការប្រើប្រាស់ដីឃុំសង្កាត់ |
| DAE | នាយកដ្ឋានផ្សព្វផ្សាយកសិកម្ម |
| DAO | ការិយាល័យកសិកម្មស្រុក |
| DIW | សិក្ខាសាលាសមាហរណកម្មថ្នាក់ស្រុក |
| D-LUP team | ក្រុមសម្របសម្រួលរៀបចំផែនការប្រើប្រាស់ដីថ្នាក់ក្រុង ខណ្ឌ ស្រុក |
| DWG | ក្រុមការងារថ្នាក់ក្រុង ខណ្ឌ ស្រុក |
| EOP | ចុងបញ្ចប់គំរោង |
| FSMIS | ប្រព័ន្ធគ្រប់គ្រងព័ត៌មានប្រព័ន្ធកសិកម្ម |
| GDA | អគ្គនាយកដ្ឋានកសិកម្ម |
| GIS | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ |
| MLMUPC | ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ |
| MOWRAM | ក្រសួងធនធានទឹក និងឧតុនិយម |
| NCDD | គណៈកម្មាធិការជាតិសំរាប់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ |
| NIO | ការិយាល័យអនុវត្តន៍គម្រោងថ្នាក់ជាតិ (Rice SDP) |
| OAE | ការិយាល័យផ្សព្វផ្សាយថ្នាក់ខេត្ត |
| PAP | ផលប៉ះពាល់លើមនុស្សរបស់គម្រោង |
| PBC | គណៈកម្មការផែនការ និងថវិកាឃុំ សង្កាត់ (village representatives) |
| PDA | មន្ទីរកសិកម្មខេត្ត |
| PIF | មូលនិធិវិនិយោគខេត្ត |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| Rice SDP | កម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ |
| RRA | ការវាយតម្លៃជនបទដោយឆាប់រហ័ស |
| RRD | នាយកដ្ឋានស្រាវជ្រាវ និងនិយតកម្ម (MLMUP) |
| SLC | ដីសម្បទានសង្គមកិច្ច |

# មាតិកា


១.សេចក្តីផ្តើម ..... 4

១.១.ប្រវត្តិ និង ទស្សនទាន ..... 4

១.២.គម្រោងកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice SDP Project) ..... 4

១.៣.ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ (CAEA) ..... 5

២.ឧបករណ៍វាយតម្លៃជនបទឆាប់រហ័ស (RRA TOOLS) ..... 7

២.១.ការផ្គូរផ្គងផែនទី( ការដាក់ផែនទីពីលើគ្នា ) ..... 8

២.២.ដ្យាក្រាមលំហូរ ..... 9

២.៣.ពំនុះកាត់ទទឹង ..... 11

២.៤.ការវិភាគប្រភពទឹក ..... 13

២.៥.ប្រវត្តិសាវតា ..... 15

២.៦.ប្រតិទិនរដូវកាលដាំដុះ ..... 16

២.៧.ការវិភាគនៃផលប៉ះពាល់ប្រែប្រួលអាកាសធាតុ ..... 18

២.៨.ការវិភាគចំណាត់ថ្នាក់ធនធាន ( ទ្រព្យសម្បត្តិ ) ..... 19

២.៩.ការវិភាគមុខងារយេនឌ័រ ..... 20

២.១០.ការវិភាគសេដ្ឋកិច្ច ..... 22

២.១១.ការគូរផែនទីខ្សែសង្វាក់ផលិតកម្ម ..... 22

២.១២.ការវិភាគអនុផលព្រៃឈើ(NTFPs) ..... 24

២.១៣.ការវិភាគផលប៉ះពាល់ ..... 24

២.១៤.ដ្យាក្រាមវែន ..... 26

២.១៥.ការវិភាគផលប៉ះពាល់ពីគម្រោងលើបុគ្គល (PAP) ..... 27

២.១៦.ចំណាត់ថ្នាក់ធនធានតំបន់ស្រោចស្របសំខាន់ៗ ..... 28

២.១៧.វិភាគការផ្សព្វផ្សាយព័ត៌មានអំពីប្រព័ន្ធស្រោចស្រប ..... 28

២.១៨.បច្ចេកទេសប្រៀបធៀបគូរបញ្ហា ..... 29

៣.ឧបករណ៍វិភាគប្រព័ន្ធ ..... 30

៣.១.ការវិភាគតាមស្វត ( ចំណុចខ្លាំង ចំណុចខ្សោយ ឱកាស ការគំរាមកំហែង ) ..... 30

៣.២.ការបង្កើតសំណួរគន្លឹះសំខាន់ៗ ..... 31

៣.៣.ការវាយតំលៃនវានុវត្ត ..... 31

៣.៤.យុទ្ធសាស្ត្រគ្រប់គ្រងធនធានដីធ្លីនិងធនធានទឹក ..... 33

៤.ការរៀបចំរបាយការណ៍ ..... 33

៥.ការអនុវត្តលើការវិភាគប្រព័ន្ធក្សេត្របរិស្ថានថ្នាក់ឃុំ ..... 35

៥.១.ការបណ្តុះបណ្តាលនិងការធ្វើតេសសាកល្បង ..... 35

៥.២.ក្រុមការងារអនុវត្តការវិភាគប្រព័ន្ធក្សេត្របរិស្ថានថ្នាក់ឃុំ ..... 35

៥.៣.តារាងពេលវេលាអនុវត្ត ..... 36

៥.៤.ការគ្រប់គ្រងប្រព័ន្ធព័តមានការវិភាគប្រព័ន្ធក្សេត្របរិស្ថានថ្នាក់ឃុំ ..... 38

## ១.សេចក្តីផ្តើម

ឯកសារនេះមានគោលបំណងសម្រាប់យកទៅប្រើដោយអ្នកអនុវត្តន៍នៅថ្នាក់មូលដ្ឋាន ហើយរៀបរាប់ពីវិធីសាស្ត្រ ដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់អនុវត្តន៍ការវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំ នៅក្រោមកម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ (Rice-SDP)។ ឧបករណ៍ និងនិតិវិធីត្រូវបានកែលំអដើម្បីធ្វើឲ្យដំណើរការប្រព្រឹត្តទៅដោយរលូន និងធ្វើឲ្យប្រសើរឡើងនូវវិធីសាស្ត្រ ហើយឆ្លើយតបទៅនឹងតម្រូវជាក់លាក់នៃកម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ (Rice-SDP) ។ ការងារនិងនិតិវិធីត្រូវបានធ្វើឲ្យមានលក្ខណៈងាយស្រួលដោយដកចេញនូវសកម្មភាពណាមិនចាំបាច់ ហើយអាចយកទៅអនុវត្តកន្លែងណាក៏បាន ។ ឧបករណ៍ដែលមានស្រាប់ត្រូវបានពង្រឹងបន្ថែម និងត្រូវបានណែនាំឲ្យស្គាល់ឧបករណ៍ថ្មីដែលឆ្លើយតបទៅនឹងអាទិភាពរបស់កម្មវិធី អភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ(Rice-SDP)។ ជាមួយនឹងការយកចិត្តទុកដាក់ជាពិសេសគឺផ្តោតទៅលើ៖ ពាណិជ្ជកម្មស្រូវ ពូជស្រូវក្រអូប បច្ចេកទេសក្រោយប្រមូលផល ខ្សែសង្វាក់នាំស្រូវអង្ករចេញ ការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ ភាពធន់នឹងអាកាសធាតុ ការកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង យន្តូបនីយកម្ម និង កម្លាំងពលកម្មដែលអាចរកបាននៅជនបទ ។ ឯកសារនេះនិងត្រូវអភិវឌ្ឍន៍បន្ថែមទៀត និងធ្វើឲ្យប្រសើរឡើងនូវ ឧបករណ៍ និងនិតិវិធីត្រូវបានសាកល្បង ព្រមទាំងមេរៀនសំរាប់រៀនពីបទពិសោធន៍ ។

### ១.១.ប្រវត្តិ និង ទស្សនទាន

ដើម្បីឆ្លើយតបនឹងតម្រូវការដល់ការផ្គត់ផ្គង់កំណើនទីផ្សារក្នុងស្រុក និងតម្លៃស្រូវខ្ពស់ កសិករបានពង្រីកផ្ទៃដីដាំដុះស្រូវក្នុងករណីមិនសមស្រប និងពេលខ្លះប៉ះពាល់ដល់តំបន់បរិស្ថានដូចជាព្រៃលិចទឹកក្នុងអាងបឹងទន្លេសាប និងដីសណ្តរទន្លេមេគង្គ ។ ដូចជាលទ្ធផលដែលទទួលបានជាបន្តបន្ទាប់ គឺត្រូវធ្វើជាប្រញាប់ចំពោះដីដែលប្រើប្រាស់នៅថ្នាក់ឃុំតាមរយៈការចំណាត់ថ្នាក់ការប្រើប្រាស់ដី ដើម្បីរក្សាតំបន់សំរាប់ផលិតកម្មស្រូវឲ្យសមស្របព្រមគ្នាជាមួយនឹងការរក្សាបាននូវបរិស្ថាន ។ ការកំណត់នូវសក្តានុពលនៃប្រពលវប្បកម្ម ផលិតកម្មដំណាំស្រូវ ត្រូវធ្វើឲ្យបានច្បាស់លាស់ចំពោះប្រភេទដីដែលមានភាពប្រសើរនិងទឹកគ្រប់គ្រាន់សំរាប់ដាំដុះបានច្រើនដង ។

ដើម្បីសំរេចបានលើគោលបំណង នៅថ្នាក់មូលដ្ឋានវាជាការចាំបាច់រួមបញ្ចូលលទ្ធផលពីការវិភាគប្រព័ន្ធក្សេត្របរិស្ថានថ្នាក់ឃុំ (CAEA) ជាមួយផែនការប្រើប្រាស់ដីឃុំ (CLUP) បានបង្កើតឡើងក្រោមអនុក្រិតឆ្នាំ ២០០៩ ។ ពាក់ ព័ន្ធក្នុងករណីនេះ វាគឺជាបំណងដែលយកលទ្ធផលពីការកែលំអវិធីសាស្ត្រវិភាគប្រព័ន្ធក្សេត្របរិស្ថានថ្នាក់ឃុំត្រូវបាន រៀបរាប់អិតនៅក្នុងឯកសារណែនាំនេះ នឹងយកទៅប្រើប្រាស់កំឡុងពេលអនុវត្តន៍ផែនការប្រើប្រាស់ដីឃុំ និងរាប់បញ្ចូលទៅក្នុងរបាយការណ៍ផែនការប្រើប្រាស់ដីឃុំដែលជាតម្រូវការស្ថិតក្រោមអនុក្រឹត្យ ។

### ១.២.គម្រោងកម្មវិធីជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ (Rice SDP Project)

កម្មវិធីជំរុញផលិតកម្ម និងការនាំចេញអង្ករ (Rice-SDP)បានអនុមតិនៅខែមិថុនាឆ្នាំ២០១៣ និងដាក់ឲ្យដំណើរការតាមអនុសាសន៍នៅវិច្ឆិកា២០១៤ ។ គម្រោងនេះនឹងដំណើរការរហូតដល់ឆ្នាំ២០២០

យោងតាមគោលនយោបាយប្រាក់កម្ចី ។ ហើយគម្រោងប្រាក់កម្ចី និងមូលនិធីឥតសំណងសម្រាប់ជួយទៅលើផ្នែកគាំទ្របច្ចេកទេស ។ គម្រោងកម្មវិធីជំរុញផលិតកម្ម និងការនាំចេញអង្ករ (Rice-SDP) អនុវត្តទៅលើខេត្តគោលដៅ៣គឺ ខេត្តបាត់ដំបង កំពង់ធំ និងខេត្តព្រៃវែង មានស្រុកគោលដៅចំនួន ១៣ស្រុក និងឃុំគោលដៅមានចំនួន ៩០ឃុំ ។មូលនិធិសរុបចំនួន៥៥.១លានដុល្លា ។

គម្រោងនេះមានគោលបំណងផ្តលប្រយោជន៍គឺ "បង្កើនប្រាក់ចំណូលរបស់អ្នកកសិស្រូវតាមរយៈខ្សែសង្វាក់តម្លៃស្រូវ" និងទទួលលទ្ធផលគឺ "បង្កើនគុណភាពផលិតកម្មស្រូវនៅក្នុងប្រទេសកម្ពុជាដោយផ្តោតលើការអភិរក្សធនធានធម្មជាតិ" ។ គម្រោងលើកឡើងនូវសន្តិសុខស្បៀង និងពាណិជ្ជកម្មស្រូវ អង្ករដោយផ្តល់អាទិភាពតាមរយៈសកម្មភាពដូចជា៖

- ពង្រឹងខ្សែសង្វាក់តម្លៃស្រូវ អង្ករ
- ការធ្វើឲ្យប្រសើរឡើងនៃបទបញ្ញាតិ និងការធ្វើត្រឹមត្រូវតាមផែនការក្នុងការគ្រប់គ្រងដីកសិកម្ម
- ការធ្វើឲ្យប្រសើរឡើងនូវសេវាផ្តល់ឥណទានដល់អ្នកផលិតពូជស្រូវ និងអ្នកកិនស្រូវ/អ្នកនាំចេញស្រូវ អង្ករ
- ការពង្រីកផលិតកម្មស្រូវ និងផលិតភាពតាមរយៈការកែលំអប្រសិទ្ធភាពប្រើប្រាស់ទឹកប្រព័ន្ធធារាសាស្ត្រ ការបង្កើតបច្ចេកទេសក្រោយប្រមូលស្រូវ និងឧបករណ៍ ព្រមទាំងការធានាគ្រាប់ពូជស្រូវតាមគោលដៅសាកល្បង ។

គម្រោងកម្មវិធីជំរុញផលិតកម្ម និងការនាំចេញអង្ករ មានលទ្ធផលចំនួន៦ដូចខាងក្រោម៖

1. ការធ្វើឲ្យប្រសើរឡើងនៃបរិស្ថានជុំវិញបទបញ្ញាតិ និងលក្ខខ័ណ្ឌច្បាប់នានា
2. ការធ្វើឲ្យប្រសើរឡើងនៃការកំណត់តំបន់ប្រើប្រាស់ដីកសិកម្ម
3. ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធខ្សែសង្វាក់តម្លៃស្រូវដែលធន់នឹងអាកាសធាតុ
4. ការធ្វើឲ្យប្រសើរឡើងនៃសេវាគាំទ្រខ្សែសង្វាក់តម្លៃស្រូវ
5. សិក្សាអំពីលទ្ធភាពដែលអាចធ្វើបាន រៀបចំនិងគោលដៅសាកល្បងនៃការធានាគ្រាប់ដំណាំ
6. ការអនុវត្ត និងការគ្រប់គ្រងគម្រោង

ស្ថាបនអនុវត្តន៍គម្រោងគឺក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងស្ថាបនអនុវត្តន៍នៅថ្នាក់ជាតិមាន ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងដែនដី នគរូបនីយកម្មនិងសំណង់ និងក្រសួងធនធានទឹកនិងឧតុនិយម ។ ការិយាល័យអនុវត្តន៍ថ្នាក់ជាតិ(NIO) និមួយៗ ត្រូវបានបង្កើតឡើងនៅក្នុងស្ថាបនថ្នាក់ជាតិទាំងបីនេះ ។ កម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុអនុវត្តន៍ក្នុង៣ខេត្តស្ថិតក្រោមផ្ទាល់របស់ការិយាល័យអនុវត្តន៍ថ្នាក់ខេត្ត(PIOs) ក្នុងនោះមានខេត្តបាត់ដំបង កំពង់ធំ និងខេត្តព្រៃវែង ហើយមានសរុប១៣ស្រុកគោលដៅ និង៩០ឃុំគោលដៅក្នុងខេត្តទាំងនេះ ។

## ១.៣.ការវិភាគប្រព័ន្ធកេ្សត្រ-បរិស្ថានឃុំ (CAEA)

ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំ គឺជាវិធីសាស្ត្រមួយវិភាគដោយមានការចូលរួមត្រូវបានប្រើប្រាស់ដោយនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ដើម្បីកំណត់ និងតម្រូវការអភិវឌ្ឍន៍កសិកម្មជាអាទិភាពនៅក្នុងឃុំ

សង្កាត់ ។ នៅក្នុងឆ្នាំ២០០៤ ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំត្រូវបានទទួលយកជាផ្លូវការស្របតាមគោលនយោបាយថ្នាក់ជាតិដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សម្រាប់រៀបចំផែនការអភិវឌ្ឍន៍កសិកម្មឃុំ សង្កាត់ ហើយបច្ចុប្បន្នបានអនុវត្តទៅលើឃុំចំនួនប្រហែល៥០០ឃុំនៅទូទាំងប្រទេស ។ ការគាំទ្រផ្តល់ថវិកាសម្រាប់អនុវត្តការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំមាន៖ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ កម្មវិធីវិមជ្ឈការ និងវិសហមជ្ឈការ(D&D)និងរួមទាំងអ្នកផ្តល់ជំនួយមាន ទីភ្នាក់ងារអូស្ត្រាលីសម្រាប់អភិវឌ្ឍន៍អន្តរជាតិ (AusAID) មូលនិធិអន្តរជាតិសម្រាប់អភិវឌ្ឍន៍កសិកម្ម (IFAD) ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គណៈកម្មការសហគមន៍អឺរ៉ុប (EC) និងអង្គការក្រៅរដ្ឋាភិបាល (NGOs) មួយចំនួនទៀត ។

កសិករកម្ពុជាប្រឈមនឹងឧបសគ្គមួយចំនួន ដូចជាបទពិសោធន៍របស់គាត់ត្រូវបានបង្ហាញឲ្យឃើញដោយការគ្រប់គ្រងប្រព័ន្ធកសិកម្មដើម្បីឆ្ពោះទៅទីផ្សារសេដ្ឋកិច្ចជនបទ ។ ក្នុងបរិបទនេះ ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំត្រូវបានទទួលយកដោយរដ្ឋាភិបាលដែលជាឧបករណ៍សំខាន់ណាស់ ដើម្បីជួយដល់កសិករក្នុងការកែលំអជីវភាពរស់នៅរបស់ពួកគាត់ឲ្យប្រសើរឡើង ធានាសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ ។ ដើម្បីសម្រេចនូវគោលបំណងនេះ ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំបង្កើតនូវលទ្ធផលសំខាន់មួយចំនួនដូចជា៖

- ការរៀបរាបនៃតំបន់ក្សេត្របរិស្ថានផ្សេងៗនៅក្នុងឃុំនិមួយៗ
- ពិពណ៌នា( ជីវៈនៃធម្មជាតិ និងសេដ្ឋកិច្ចសង្គម )របស់តំបន់ក្សេត្របរិស្ថានទាំងអស់ក្នុងឃុំ
- ធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងនៃប្រព័ន្ធកសិកម្មសំខាន់ៗ និងប្រព័ន្ធជីវភាពរស់នៅក្នុងតំបន់និមួយៗ
- កត់ត្រានូវអាទិភាពនៃបញ្ហា និងឱកាសពីតំបន់និមួយៗដែលបានរកឃើញដោយកសិករក្នុងភូមិ
- យុទ្ធសាស្ត្រគ្រប់គ្រងប្រើប្រាស់ដីសម្រាប់តំបន់ក្សេត្របរិស្ថាននិមួយៗបានដាក់បញ្ចូលនៃគោលបំណងអភិវឌ្ឍន៍ និងការការពារបរិស្ថាន
- កត់ត្រានូវអាទិភាពនៃផែនការផ្សព្វផ្សាយកសិកម្មដើម្បីដោះស្រាយបញ្ហាបានរកឃើញ ។

ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំគឺត្រូវបានអនុវត្តន៍ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ដោយមានការចូលរួមពីក្រុមមន្ត្រីថ្នាក់ខេត្ត និងថ្នាក់ស្រុក ចាប់ផ្តើមជាមួយការគាំទ្រពីការិយាល័យប្រព័ន្ធកសិកម្មនៃនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម ។ ការវិភាគប្រព័ន្ធក្សេត្រ-បរិស្ថានឃុំគឺប្រើប្រាស់ដើម្បីកំណត់បាននូវប្រព័ន្ធក្សេត្រ-បរិស្ថានសំខាន់ៗនៅក្នុងឃុំ និងបង្កើនការយល់ដឹងទូទៅអំពីតួនាទីរបស់ពួកគេ ដើម្បីនឹងកំណត់បញ្ហាគន្លឹះ ឬសំណួរគន្លឹះនានាដែលប៉ះពាល់លើការអនុវត្តរបស់គេ ។ សំណួរគន្លឹះត្រូវបានយកទៅបង្កើតបច្ចេកវិជ្ជាសមស្របប្រើប្រាស់នៅពេលអន្តរាគមន៍សម្រាប់ដាក់បញ្ចូលទៅក្នុងផែនការអភិវឌ្ឍន៍ឃុំសង្កាត់(CDP) ឬ កម្មវិធីវិនិយោគឃុំសង្កាត់ (CIP) សម្រាប់អនុវត្តន៍កម្មវិធីផ្សព្វផ្សាយកសិកម្ម ដើម្បីគាំទ្រតាមរយៈមូលនិធិវិនិយោគខេត្ត (PIF) នៃគណៈកម្មាធិការជាតិដឹកនាំការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ( NCDD) ។

## ២.ឧបករណ៍វាយតម្លៃជនបទឆាប់រហ័ស (RRA TOOLS)

ក្នុងការជួបជាមួយមន្ត្រីដែលមានបទពិសោធន៍ ការធ្វើវិភាគប្រព័ន្ធកេ្សត្របរិស្ថានឃុំក្នុងនាយកដ្ឋាន ផ្សព្វផ្សាយកសិកម្មអំពីឧបករណ៍វាយតម្លៃជនបទឆាប់រហ័សសំខាន់ៗ ដែលបានរៀបរាប់នៅក្នុងឯកសារណែនាំឆ្នាំ២០១០ ជាភាសាខ្មែរត្រូវបានកែលំអ ធ្វើបច្ចុប្បន្នភាព និងការផ្លាស់ប្តូរឲ្យប្រសើរជាងមុន ដើម្បីឆ្លើយតបនឹងតម្រូវការរបស់គម្រោងកម្មវិធីជំរុញផលិតកម្ម និងការនាំចេញអង្ករ (Rice-SDP) ។ ឧបករណ៍ដែលមានសារៈសំខាន់ត្រូវបានពង្រឹងបន្ថែម ឧបករណ៍ថ្មីត្រូវបានណែនាំឲ្យស្គាល់ និងឧបករណ៍មួយចំនួនដែលមិនសំខាន់ត្រូវបានដកចេញឬបញ្ចូលគ្នា ។ ជាលទ្ធផលគឺធ្វើឲ្យអ្នកយល់ច្បាស់ សាមញ្ញ និងទាក់ទងវិធីសាស្ត្រ ដែលឆ្លើយតបនឹងតម្រូវការផ្លាស់ប្តូរយ៉ាងរហ័សពេលបច្ចុប្បន្ន និងឆ្លើយតបយ៉ាងប្រសើរផងដែរទៅអាទិភាពសំខាន់ៗនៃគម្រោងកម្មវិធីជំរុញផលិតកម្ម និងការនាំចេញអង្ករ (Rice-SDP) ។

ជាលទ្ធផលគឺឧបករណ៍ចូលរួមវិភាគទាំង១៦បានកែប្រែ ដែលមានទំនាក់ទំនងគ្នាទៅវិញទៅមក និងយកអនុវត្តន៍ជាមួយព័ត៌មានសំខាន់ៗបានមកពីឃុំនៅក្នុងលក្ខណះច្បាស់លាស់ និងសមស្របបំផុត ។ ឧបករណ៍ដែលធ្លាប់មាន និងមួយចំនួន បានផ្លាស់ប្តូរត្រូវបានបង្ហាញនៅក្នុងតារាងខាងក្រោម៖

| ឧបករណ៍CAEA | ការកែប្រែឧបករណ៍សម្រាប់យកទៅអនុវត្តន៍ |
|---|---|
| ផ្គូរផ្គងផែនទី( ដាក់ត្រួតលើគ្នា ) | ប្តូរពីការគូផែនទីដោយប្រើដៃជំនួសដោយផែនទីបោះពុម្ព(ប្រើក្នុងកំព្យូទ័រ) |
| ដ្យាក្រាមលំហូរ | ដែលបន្ថែមដ្យាក្រាមនេះសម្រាប់ដាក់បន្ថែមព័ត៌មានស្រូវ អង្ករ |
| ពំនុះកាត់ទទឹង | បានពង្រឹងបន្ថែមសម្រាប់ការដាំដុះស្រូវពូជ និងផលប៉ះពាល់ប្រែប្រួលអាកាសធាតុ |
| ការវិភាគប្រភពទឹក | ឧបករណ៍ចាស់ត្រូវបានពង្រឹងបន្ថែម និងធ្វើឲ្យងាយស្រួល |
| ប្រវត្តិឃុំ | កែលំអទាំងស្រុងនិងត្រូវបានពង្រឹងបន្ថែមសម្រាប់អាកាសធាតុ និងពាណិជ្ជកម្មស្រូវ |
| ប្រតិទិនរដូវកាលដាំដុះ | បានពង្រឹងបន្ថែមសម្រាប់ប្រព័ន្ធកេ្សត្របរិស្ថានស្រូវ និងពេលវេលាកើតមានប្រែប្រួលអាកាសធាតុ |
| ការវិភាគផលប៉ះពាល់អាកាសធាតុ | ជាឧបករណ៍ថ្មីទាំងស្រុងដែលវិភាគផលប៉ះពាល់ និងការប្រែប្រួលទៅតាមយុទ្ធសាស្ត្រ |
| ការវិភាគចំណាត់ថ្នាក់ធនធាន | ឧបករណ៍ចាស់ |
| ការវិភាគចំណាត់ថ្នាក់ធនធានដីធ្លី | ឧបករណ៍ចាស់ត្រូវពង្រឹងបន្ថែមធ្វើឲ្យកាន់តែល្អប្រសើរអាស្រ័យលើជីសម្បទានសង្គមកិច្ច |
| ការវិភាគយេនឌ័រ | ឧបករណ៍ចាស់ងាយស្រួល និងទៅតាមលំដាប់លំដោយ |
| ការប្រើប្រាស់អនុផលព្រៃឈើ | ឧបករណ៍ចាស់ |
| ការវិភាគខ្សែសង្វាក់ផលិតកម្ម/ទីផ្សារ | ឧបករណ៍ចាស់ត្រូវពង្រឹងបន្ថែមធ្វើឲ្យកាន់តែល្អប្រសើរអាស្រ័យលើខ្សែសង្វាក់ទីផ្សារនាំស្រូវអង្ករចេញ |
| ការវិភាគផលប៉ះពាល់នៃបញ្ហា | ឧបករណ៍ចាស់ហើយសមស្រប |
| ដ្យាក្រាមវ៉ែន | ឧបករណ៍ចាស់ |
| ផ្សព្វផ្សាយព័ត៌មានអនុគម្រោង | ឧបករណ៍ថ្មីសម្រាប់វិភាគការយល់ដឹងពីផលប៉ះពាល់ពីអនុគម្រោង Rice-SDP |
| ការវិភាគធនធាននៅតំបន់ស្រោចស្រប | ឧបករណ៍ថ្មីដែលវិភាគចំណាត់ថ្នាក់ធនធានពីការកាន់កាប់ដីមានការស្រោចស្រប |

| | |
|---|---|
| ការវិភាគផលប៉ះពាល់គម្រោងលើបុគ្គល | ឧបករណ៍ថ្មីដែលរកឃើញផលប៉ះពាល់ជាវិជ្ជមាន និងអវិជ្ជមានពីការអភិវឌ្ឍន៍ប្រព័ន្ធធារាសាស្ត្រ |
| ការប្រៀបធៀបគូបញ្ហា | ឧបករណ៍ចាស់ |

## ២.១.ការផ្គូរផ្គងផែនទី( ការដាក់ផែនទីពីលើគ្នា)

### ការកែសម្រួលឧបករណ៍

ការវិភាគផ្គូរផ្គងផែនទី ត្រូវបានពង្រឹងបន្ថែមតាមរយៈនៃការប្រើប្រាស់ផែនទីនិយាមជាក់លាក់តាមបច្ចេកទេសប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (digital maps using GIS techniques)។ ក្នុងដំណើរការនៃការអនុវត្តទៅតាមជំហានមានដូចខាងក្រោម៖

1. បើអាចរកបានរូបភាពផែនទីផ្កាយរណបដែលមាននិងបោះពុម្ពសម្រាប់ឃុំ
2. បោះពុម្ពផែនទីឃុំ និងបញ្ជាក់ច្បាស់នូវរាល់ចំណុចទីតាំងទាំងអស់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់
3. ដាក់ផែនទីឃុំត្រួតលើគ្នាទាំងអស់ និងប្រើបន្ទាត់កាត់ទទឹង ដើម្បីកំណត់តំបន់ប្រព័ន្ធក្សេត្របរិស្ថាន
4. បន្តជាមួយការដាក់ផែនទីឃុំត្រួតលើគ្នាដើម្បីធ្វើឲ្យកាន់តែច្បាស់នូវព្រំប្រទល់តំបន់ប្រព័ន្ធក្សេត្របរិស្ថាន
5. ត្រួតពិនិត្យ នៅពេលគូរផែនទីពង្រៀងតំបន់ប្រព័ន្ធក្សេត្របរិស្ថាននឹងឈានទៅបង្កើតសំណុំផែនទី ដែលមានទ្រង់ទ្រាយជាលំដាប់ដោយការប្រើប្រាស់ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ GIS.
6. ប៉ានប្រមានលក្ខណៈសំខាន់ៗនៃតំបន់ប្រព័ន្ធក្សេត្របរិស្ថាននិមួយៗ ។ ជាឧទាហរណ៍៖
   - តំបន់ទី១ ស្រូវរដូវវស្សា=..ហិកតា? ដំណាំ=..ហិកតា? ផ្ទៃដីស្រោចស្រប=..ហិកតា? ។ល។
   - តំបន់ទី២ ស្រូវរដូវប្រាំង=..ហិកតា?ដំឡូង=..ហិកតា? និងដោះស្រាយផលប៉ះពាល់=..ហិកតា ។ល។
   - បន្តទៅតំបន់ទី៣ ទី៤ ។ល។

### របៀបកត់ត្រា

ព័ត៌មានផ្នែកតូចៗគឺត្រូវបានកត់ត្រាដោយការប្រើប្រាស់ផែនទីលើក្រដាស់ និងផែនទីពង្រៀងដូចបានបង្ហាញនៅក្នុងឧទាហរណ៍ខាងក្រោម ។

### ឧទាហរណ៍ឯកសារមេរៀនបណ្ដុះបណ្ដាលថ្មី

ប្រើឧទាហរណ៍ខាងក្រោមសម្រាប់បង្កើតមេរៀនបណ្ដុះបណ្ដាលថ្មីសម្រាប់ការផ្ទួរផ្គងផែនទី ។

AEA Zone




Satellite Image




Land Use




Water Resource




Soil Type




Topology map




## ២.២.ដ្យាក្រាមលំហូរ

ដ្យាក្រាមលំហូរចាស់ត្រូវបានកែប្រែ និងដ្យាក្រាមលំហូរថ្មីនេះគឺបន្ថែមការវិភាគលំហូរព័ត៌មាន ។ បន្ទាប់ពីការបំពេញដ្យាក្រាមលំហូរចប់សព្វគ្រប់ សមាជិកក្រុមវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំគួរតែពិភាក្សាជាមួយអ្នកផ្ដល់ព័ត៌មានសំខាន់ៗ និងជ្រើសរើស៥បញ្ហាសំខាន់ជាងគេដែលបានរកឃើញ ។

### ការកែសម្រួលឧបករណ៍

- កែប្រែគំរូដ្យាក្រាមលំហូរសម្រាប់លំហូរឡើងនិងចុះ ឋានានុក្រមលំហូរបានបង្ហាញខាងក្រោម។
- បន្ថែមដ្យាក្រាមលំហូរនិយាយពីព័ត៌មានលំហូរជាក់លាក់ជាមួយការបញ្ជាក់លើការណែនាំផ្សព្វផ្សាយស្រូវអង្ករ និងព័ត៌មានខ្សែសង្វាក់ទីផ្សារស្រូវជាមួយ " **កសិករ** " ដែលដាក់នៅចំកណ្ដាលធាតដូចបានបង្ហាញនៅក្នុងឧទាហរណ៍ខាងក្រោម ។
- ប្រើប្រាស់ឧទាហរណ៍នៅក្នុងទំព័រខាងក្រោមដើម្បីបង្កើតមេរៀនបណ្ដុះបណ្ដាលជាភាសាខ្មែរ។

### របៀបកត់ត្រា

ប្រើទ្រង់ទ្រាយកត់ត្រាដូចពីមុន សម្រាប់ដ្យាក្រាមលំហូរពីតំបន់ក្សេត្របរិស្ថានមួយទៅតំបន់ក្សេត្របរិស្ថានមួយទៀតនិងសម្រាប់លំហូរឡើង និងចុះដូចនឹងឋានានុក្រម ។ បង្កើតទ្រង់ទ្រាយកត់ត្រាថ្មីមួយសម្រាប់លំហូរព័ត៌មានជាមួយ"**កសិករ**" ដែលដាក់នៅចំកណ្តាលដ្យាក្រាមដូចបានបង្ហាញនៅក្នុងឧទាហរណ៍ខាងក្រោម ។

### ឧទាហរណ៍ឯកសារមេរៀនបណ្តុះបណ្តាលថ្មី

ប្រើឧបករណ៍ចាស់សន្រាប់លំហូររវាងតំបន់ក្សេត្របរិស្ថាន និងកែប្រែគំរូដ្យាក្រាមលំហូរសម្រាប់ឋានានុក្រមលំហូរឡើងនិងចុះដូចបានបង្ហាញក្នុងឧទាហណ៍ខាងក្រោម។ ប៉ុន្តែព័ត៌មានដាក់ចូលបានហូរទៅមកទាំងសង្ខាងនៃដ្យាក្រាមនេះ។

ដ្យាក្រាមលំហូរពីតំបន់មួយទៅមួយទៀត






ប្រើទ្រង់ទ្រាយកត់ត្រាដូចពីមុន សម្រាប់លំហូរពីតំបន់ក្សេត្របរិស្ថានមួយទៅក្សេត្របរិស្ថានមួយទៀត និងសម្រាប់លំហូរឡើងនិងចុះដូចនឹងឋានានុក្រម ប៉ុន្តែដាក់ព័ត៌មានលំហូរក្នុងចន្លោះនោះ ។ ប្រើឧទាហរណ៍ខាងក្រោមក្នុងការបង្កើតមេរៀនបណ្តុះបណ្តាលថ្មីសម្រាប់លំហូរព័ត៌មាន ។

ដ្យាក្រាមលំហូរព័តមានៈឧទាហរណ៏យកចេញពីឃុំ ព្រៃញ្ចៅ ខេត្តព្រៃវែង




## ២.៣.ពំនុះកាត់ទទឹង

ពំនុះកាត់ទទឹងគឺប្រើប្រាស់ដូចពីមុន ប៉ុន្តែពង្រីកបញ្ចូលបន្ថែមធនធានទឹក ពូជស្រូវ និងផលប៉ះពាល់បម្រែបម្រួលអាកាសធាតុស្ថិតនៅក្នុងតម្រូវការគេម្រោងកម្មវិធីជំរុញផលិតកម្ម និងការនាំចេញអង្ករ ។ បន្ទាប់ពីបំពេញតារាងពំនុសកាតើទទឹង សមាជិកក្រុមវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំគួរតែពិភាក្សាជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងជ្រើសរើស៥បញ្ហាសំខាន់ជាងគេដែលបានរកឃើញ ។

### ការកែសម្រួលឧបករណ៍

- បន្ថែមកូឡោនជួរដេកសម្រាប់ព័ត៌មានធនធានទឹកនៅក្នុងតារាង និងរកឲ្យឃើញឱកាសសម្រាប់អភិវឌ្ឍន៍ក្នុង
  តំបន់និមួយៗ ។ ពិនិត្យឡើងវិញពីលទ្ធផលជាមួយផែនទីប្រើប្រាស់ដី និងលទ្ធផលការវិភាគប្រភពទឹក ។
- បន្ថែមកូឡោនជួរដេកសម្រាប់ដាក់ដាំដុះប្រភេទពូជស្រូវ( ដាក់ក្នុងវង់ក្រចកសម្រាប់លក់ឬហូបចុក) ដើម្បីកាន់តែល្អរកឲ្យឃើញតម្រូវការ និងឱកាសពាណិជ្ជកម្មស្រូវ អង្ករសម្រាប់ស្រូវពូជក្រអូប ។

- បន្ថែមកូឡោនជួរដេកសម្រាប់ផលប៉ះពាល់សំខាន់ៗទាក់ទងនឹងអាកាសធាតុ (បញ្ជាក់ខែក្នុងវង់ក្រចក) និងថាតើកសិករមានភាពធន់យ៉ាងណា ដើម្បីធ្វើឲ្យបានល្អទៅនឹងបម្រែបម្រួលអាកាសធាតុ ។
- បញ្ចូលព័ត៌មានសំខាន់ទាំងអស់ពីផែនការប្រើប្រាស់ដីឃុំ ផែនទីឃុំក្នុងពំនុះកាត់ទទឹងទៅក្នុងកូឡោនជួរដេក/ឈរបានត្រឹមត្រូវ ។

## របៀបកត់ត្រា

ប្រើទ្រង់ទ្រាយកត់ត្រាដូចពីមុនសម្រាប់ពំនុះកាត់ទទឹង ប៉ុន្តែកូឡោនជួរដេកសម្រាប់ទិន្នន័យធនធានទឹក ប្រភេទពូជស្រូវ និងផលប៉ះពាល់អាកាសធាតុ ដូចបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម ។

## ឧទាហរណ៍ឯកសារមេរៀនបណ្តុះបណ្តាលថ្មី

ពំនុះកាត់ទទឹងសម្រាប់ឯកសារមេរៀនបណ្តុះបណ្តាលប្រើដូចមុន ប៉ុន្តែបង្កើតទិន្នន័យថ្មីសម្រាប់ធនធានទឹក ប្រភេទពូជស្រូវ និងបម្រែបម្រួលអាកាសធាតុ ដូចបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម

| | តំបន់ក្សេត្របរិស្ថាន ១ | តំបន់ក្សេត្របរិស្ថាន ២ | តំបន់ក្សេត្របរិស្ថាន ៣ | តំបន់ក្សេត្របរិស្ថាន ៤ | តំបន់ក្សេត្របរិស្ថាន ៥ |
|---|---|---|---|---|---|
| រូបថត | | | | | |
| ឈ្មោះតំបន់ | តំបន់ទំនាបខ្ពស់ស្រូវវស្សាស្រោចស្រប់ដោយទឹកភ្លៀងនិងដំណាំខ្ពង់រាប | តំបន់តំនាបខ្ពស់/មធ្យមស្រូវវស្សាស្រោចស្របដោយប្រព័ន្ធ ប្រឡាយ ផ្នែកខ្លះ | តំបន់លំនៅដ្ឋាននិងសួនបន្លែតាមផ្ទះ | តំបន់ទំនាបទាប មធ្យមដំណាំប្រពលវប្បកម្មធ្វើបានបីដងស្រោចស្រប់ដោយប្រព័ន្ធប្រឡាយ | តំបន់ទំនាបទាប មធ្យមដាំដុះស្រូវពីរដង ស្រោចស្រប់ដោយប្រព័ន្ធប្រឡាយ |
| រៀបរាបដោយសង្ខេប | សណ្ឋានដីរាងរមៀល ជំរាលតំបន់ទំនាបខ្ពស់ ស្រោចស្រប់ដោយទឹកភ្លៀងមានភ្លឺស្រែខ្លះ និងតំបន់ដំណាំខ្ពង់រាប<br>ផ្ទៃដី ១៩៩០ ហ.ត | សណ្ឋានរាបស្មើ តំបន់ស្រូវទំនាបខ្ពស់និងមធ្យម ដីស្រែមានភ្លឺត្រឹមត្រូវ<br>ផ្ទៃដី ៥២៧០ ហ.ត | តំបន់លំនៅដ្ឋាននៅជិតផ្លូវមានផ្ទះនិងសួនដំណាំបន្លែតាមផ្ទះ<br>ផ្ទៃដី ៣៧០ ហ.ត | តំបន់ស្រោចស្រប់ដោយប្រព័ន្ធប្រឡាយ តំបន់ជំរាលទំនាបទាបដាំដុះស្រូវពីរដងនិង ដំណាំយកប្រាក់មួយដង<br>ផ្ទៃដី៤៩៥ ហ.ត | សណ្ឋានជំរាល ស្រោចស្រប់ដោយប្រព័ន្ធប្រឡាយ តំបន់ទំនាបមធ្យមនិងទាបដាំដុះស្រូវ<br>ផ្ទៃដី ១៤៨០ ហ.ត |
| ឋានលេខា | តំបន់ទំនាបខ្ពស់មានសណ្ឋានរាបស្មើនិងមានសណ្ឋានខ្ពស់ទាបដូចទឹករលក | តំបន់ទំនាបខ្ពស់និង មធ្យមមានសណ្ឋានរាបស្មើ ហើយមានសណ្ឋានខ្ពស់ទាបដូចទឹករលកមានភ្លឺស្រែ | តំបន់ទំនាបមធ្យមមានសណ្ឋានរាបស្មើសំរាប់លំនៅដ្ឋាននិងសួនដំណាំតាមផ្ទះ | តំបន់ទំនាបទាបមធ្យមមានសណ្ឋានរាបស្មើ ដីស្រែមានភ្លឺត្រឹមត្រូវ | តំបន់ទំនាបទាបមធ្យមមានសណ្ឋានរាបស្មើ ដីស្រែមានភ្លឺត្រឹមត្រូវ |
| ប្រភេទដី | ប្រភេទដី ក្រុមអូររូង សមស្របសំរាប់ផលិតកម្មស្រូវ ងាយស្រួលគ្រប់គ្រង ដីមានជីជាតិ | ប្រភេទដី ក្រុមអូររូងនិងទួលសំរោង ដីមានជីជាតិ សមស្របសំរាប់ផលិតកម្មស្រូវ ងាយស្រួលគ្រប់គ្រង | ប្រភេទដី ក្រុមទួលសំរោង ដីមានជីជាតិសំរាប់សួនដំណាំតាមផ្ទះ | ប្រភេទដី ក្រុមទួលសំរោង សមស្របសំរាប់ផលិតកម្មស្រូវ ងាយស្រួលគ្រប់គ្រង ដីមានជីជាតិបំផុត | ច្រើនតែប្រភេទដី ក្រុមទួលសំរោង ដីមានជីជាតិបំផុត |
| ជលសាស្ត្រ | ស្រោចស្រប់ដោយទឹកភ្លៀង តំបន់មិនមានទឹកជំនន់ | ស្រោចប្រព័ន្ធប្រឡាយដោយផ្នែក មានទឹកជំនន់តាមរដូវកាល ជំនន់រយះពេលខ្លីនៅក្នុងខែកញ្ញានិងខែតុលា | ស្រោចប្រព័ន្ធប្រឡាយ មានទឹកជំនន់តាមរដូវកាល(នៅក្នុងខែកញ្ញានិងខែតុលា) | ស្រោចប្រព័ន្ធប្រឡាយ មិនមានទឹកជំនន់ | ស្រោចប្រព័ន្ធប្រឡាយជាសំខាន់ ដីទឹកលិចតាមរដូវកាល មិនមានទឹកជំនន់ |
| ធនធានទឹក | មានបឹង មានកូនអូរពីរនិងប្រឡាយមួយ | មានបឹង មានស្ទឹងតូចៗនិងប្រឡាយខ្លះ | មានស្ទឹងធំ មានអូរភ្ជាប់ស្ទឹងទៅប្រឡាយនិងប្រឡាយស្រោចស្រប់មានអណ្តូបចេញច្រើន | ស្រោចស្រប់បានទាំងអស់ មានអូរនិងមានប្រប្រព័ន្ធប្រឡាយ មានអណ្តូងស្នប់បួន | ប្រឡាយ មានស្ទឹងតូចស្ថិតនៅផ្នែកខាងត្បូង |

| | | | | | |
|---|---|---|---|---|---|
| គំរូបដី/ការប្រើប្រាស់ដី | មានព្រៃឈើតូចៗពីរកន្លែង ដំណាំស្រូវនិងដំណាំខ្ពង់រាបលាយជាមួយដើមឈើសល់ខ្លះៗ ព្រៃកំពតនិងវាលស្មៅ | មានដំណាំស្រូវនិងមានផលិតកម្មដំណាំខ្ពង់រាបតិចតួច | មានដីស្រែក្រោមប្រព័ន្ធប្រឡាយ លំនៅដ្ឋាន ច្បារដំណាំ ផ្លូវថ្នល់និងផ្លូវជាតិ | ប្រពលវប្បកម្មដំណាំធ្វើបានបីដង (ស្រូវ ដំណាំឆ្លងកាត់ ស្រូវ) ជាតំបន់ផលិតកម្មពូជរបស់សហគមន៍កសិកម្ម | ធ្វើស្រែបានពីរដង។ ជាតំបន់ផលិតកម្មពូជរបស់សហគមន៍កសិកម្ម |
| ដំណាំសំខាន់ៗ | ដំណាំស្រូវតែមួយមុខ ធ្វើស្រែបានពីរដង ដំណាំដំឡូងមី សណ្តែក ឪឡឹក | ដាំដុះស្រូវបានពីរដង ដាំដំឡូងជ្វា | ដំណាំស្រូវ សណ្តែកគួរ ត្រប់វែង ននោង ឈើហូបផ្លែ (ដូច ស្វាយ ក្រូច) | ដំណាំស្រូវ ដំណាំឆ្លងកាត់ (ឪឡឹក បន្លែ ត្រសក់ ត្រប់វែង ដំឡូងជ្វា ម្ទេស) | ដំណាំស្រូវធ្វើបានពីរដង ជាមួយនឹងដំណាំដំឡូងជ្វា នៅក្នុងផ្ទៃដីតិចតួច |
| ពូជស្រូវ | ពូជស្រូវផ្ការំដួល (កាឌី) ពូជស្រូវស្រាវែង (ពូជកែលំអរ) ទិន្នផលពី៤ទៅ៥ ត/ហ.ត ដោយវិធីសាស្ត្រព្រោះ | ពូជស្រូវផ្ការំដួល (កាឌី) ពូជស្រូវសែនក្រអូប(ពូជកែលំអរ) ពូជនាងខុន (ពូជក្នុងស្រុក) ពូជផ្កាខ្ញីធ្វើដោយព្រោះ | មិនមានដំណាំស្រូវ | ពូជស្រូវសែនក្រអូប(ពូជកែលំអរ)ពូជនាងខុន (ពូជក្នុងស្រុក) ពូជស្រូវផ្ការំដួល (១០ ហ.ត) ដោយព្រោះនិងស្ទូងសំរាប់ផលិតកម្មពូជ | ពូជស្រូវសែនក្រអូប(ពូជកែលំអរ) ពូជស្រូវផ្ការំដួល |
| ការប្រើប្រាស់ជី | ប្រើជី 16-20-0 (៥០ គ.ក្រ/ហ.ត) ជីអ៊ុយរ៉េ មិនមានប្រើជីកំប៉ុស្តិ៍ឡើយ | ប្រើជី DAP 18-46-0(៥០ គ.ក្រ/ហ.ត) ជីអ៊ុយរ៉េ (១៥០គ.ក្រ/ហ.ត) បាចពីរដង | ប្រើជីច្រើនប្រភេទនិងក្នុងសួនបន្លែនិងឈើហូបផ្លែ | ប្រើជី DAP 18-46-0(៥០ គ.ក្រ/ហ.ត) ជីអ៊ុយរ៉េ (៥០គ.ក្រ/ហ.ត)បាចពីរដងក្នុងដំណាំស្រូវមួយវគ្គ (ធ្វើពីរដង) | ប្រើជី DAP 18-46-0(៥០ គ.ក្រ/ហ.ត) ជីអ៊ុយរ៉េ (១៥០គ.ក្រ/ហ.ត)បាចពីរដង |
| ការចិញ្ចឹមសត្វ | គោ ពពែ ជ្រូក មាន់ ទា | គោ(ចំនួនថយចុះ) មាន់ ទា | គោ ជ្រូកមេ និងជ្រូកសាច់ មាន់ ទា | គោ ជ្រូកមេ និងជ្រូកសាច់ មាន់ ទា | គោ ជ្រូកមេ និងជ្រូកសាច់ មាន់ ទា |
| ដីរបស់រដ្ឋឬដីសហគមន៍ | តំបន់ព្រៃសហគមន៍មានពីរកន្លែង(៣០ ហ.តនិង១០ ហ.ត) | កំណែទំរង់ព្រំប្រទល់រដ្ឋបាល និងនឹងកាត់ដីទំហំ៤០០០ ហ.តចេញពីតំបន់នេះទៅឲ្យឃុំបវេល | ដីទំហំ ០,៣ ហ.តត្រូវបានបែងចែកទៅឲ្យ១២គ្រួសារដែលគ្មានដីសំរាប់លំនៅដ្ឋានដោយរដ្ឋាភិបាល | គ្មានមនុស្សរស់នៅ | គ្មានមនុស្សរស់នៅ |
| បញ្ហាផ្សេងៗ | ដង្កូវស៊ីរូងដើមនិង ដង្កូវកាត់ស្លឹក គ្រោះរាំងស្ងួត ពុំមានប្រព័ន្ធស្រោចស្រប់ បទល្មើសនេសាទ ដីមានមីន តំលៃស្រូវថោក | ជំងឺប្លាស់ ដង្កូវស៊ីរូងដើមនិងដង្កូវកាត់ស្លឹក សត្វល្អិតបំផ្លាញគ្រោះរាំងស្ងួត ពុំមានប្រព័ន្ធស្រោចស្រប់ តំលៃស្រូវថោក | ជំងឺប្លាស់ ដង្កូវស៊ីរូង ខ្មូងដូង ទឹកជំនន់នៅរដូវវស្សា ពុំមានទឹកគ្រប់គ្រាន់ក្នុងរដូវប្រាំង | ដង្កូវកាត់ស្លឹក ដង្កូវស៊ីរូងដើម ការគូរប្លង់និងសាងសង់ប្រព័ន្ធស្រោចស្រប់ពុំល្អ ក្រុមកសិករប្រើប្រាស់ទឹកនៅមានភាពទន់ខ្សោយ | ពុំមានទំនុកចិត្តប្រព័ន្ធស្រោចស្រប់មិនគ្រប់គ្រាន់ ដង្កូវស៊ីរូងដើមនិង សត្វល្អិតបំផ្លាញស្លឹក |
| កាឡានុវត្តភាព/ឱកាស | ធនធានធម្មជាតិនិងអេកូទេសចរណ៍ ដាំដំណាំល្មមុននឹងធ្វើស្រែ ពង្រីកផ្ទៃដំណាំស្រូវ/ដំឡូងមី អភិរក្សព្រៃឈើ ដោះមីន | ការកែលម្អប្រព័ន្ធស្រោចស្រប់ ពង្រីកផ្ទៃដីដាំដុះស្រូវបន្ទាប់ពីការអភិវឌ្ឍន៍ប្រព័ន្ធស្រោចស្រប់ ដាំដុះដំណាំឆ្លងកាត់បន្ទាប់ពីដំណាំស្រូវ (ឪឡឹក ត្រប់វែង) | ការកែលំអរប្រព័ន្ធស្រោចស្រប់ ពង្រីកផ្ទៃដីដាំដុះដំណាំឈើហូបផ្លែ បង្កើនការចិញ្ចឹមសត្វ កែលម្អសួនដំណាំគ្រួសារ | បង្កើនផ្ទៃដីដាំដុះស្រូវផ្ការំដួលសំរាប់លក់ក្នុងតំលៃខ្ពស់ បង្កើនផលិតកម្មដំណាំឆ្លងកាត់ | ការកែលំអរប្រព័ន្ធស្រោចស្រប់ កែលម្អការគ្រប់គ្រងជីជាតិដី ដុះដំណាំឆ្លងកាត់បន្ទាប់ពីដំណាំស្រូវ (ដំឡូងជ្វា) |

## ២.៤.ការវិភាគប្រភពទឹក

ការវិភាគប្រភពទឹកនៅក្នុងវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំ គឺត្រូវបានរក្សាទុកជួយដល់ការអភិវឌ្ឍធារាសាស្ត្រ ឬធនធានទឹកក្នុងកម្មវិធីជំរុញផលិតកម្ម និងការនាំចេញអង្ករ(Rice-SDP) សម្រាប់ពាណិជ្ជកម្មស្រូវអង្ករ ។ ការវិភាគនេះ ត្រូវបន្ថែមកូឡោនជួរដេកថ្មី យកទៅប្រើប្រាស់វិភាគប្រភពទឹកផ្សេងៗសម្រាប់ផលិតកម្មដំណាំស្រូវ ការជួបប្រទះបញ្ហាសំខាន់ៗ និងឱកាសសម្រាប់អភិវឌ្ឍន៍ ។ ឧបករណ៍នេះត្រូវបានសម្រួលផងដែរដោយយកចេញនៅកូឡោនខ្លះ(ព័ត៌មានមិនមាននៅក្នុងតំបន់នោះ) ដូចបានបង្ហាញក្នុងឧទាហរណ៍

ខាងក្រោម ។

បន្ទាប់ពីបានបំពេញការវិភាគប្រភពទឹក សមាជិកក្រុមវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំគួរតែពិភាក្សាជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងជ្រើសរើស៥បញ្ហាសំខាន់ជាងគេដែលបានរកឃើញ ។

## ការកែសម្រួលឧបករណ៍

សម្រាប់ធនធានទឹកសំខាន់និមួយៗ កំណត់ថាតើការប្រើប្រាស់ធនធានទឹកយ៉ាងណាក្នុងផលិតកម្មដំណាំស្រូវនិងបញ្ហាខ្លះ ដែលទាក់ទងឱកាសអភិវឌ្ឍន៍នេះ ។

## របៀបកត់ត្រា

ប្រើរបៀបកត់ត្រាដូចមុនត្រូវបានកែប្រែដូចបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម ។

## ឧទាហរណ៍ឯកសារមេរៀនបណ្តុះបណ្តាលថ្មី

ប្រើប្រាស់ឯកសារមេរៀនបណ្តុះបណ្តាលប្រើដូចមុនសម្រាប់ការវិភាគប្រភពទឹក ប៉ុន្តែបន្ថែមកូឡោនសម្រាប់ប្រើប្រាស់ទឹកក្នុងផលិតកម្មដំណាំស្រូវដូចបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម។

ឧទាហរណ៍តារាងការកំណត់វិភាគប្រភពទឹក

| ប្រភពទឹក / ការកំណត់ | ទន្លេ | ស្ទឹង/អូរ | បឹង/ត្រពាំង | ប្រឡាយ | ស្រះទឹក | វាលស្រែ |
|---|---|---|---|---|---|---|
| តំបន់ក្សេត្របរិស្ថានប្រភពទឹកកើតមកពីណា | | | | | | |
| ប្រើប្រាស់ទឹកសម្រាប់ផលិតកម្មដំណាំស្រូវ | រកឲ្យឃើញធនធានទឹកនៃប្រភពនិមួយៗតើទឹកត្រូវបានប្រើយ៉ាងម្តេចក្នុងផលិតកម្មដំណាំស្រូវនិងស្រង់យកបញ្ហាកើតមានខ្លះនៅក្នុងនោះ | | | | | |
| ឧទាហរណ៍ | ប្រើម៉ាស៊ីនបូមទឹកពីស្ទឹង/ទន្លេសង្គ្រោះរាំងស្ងួតស្រូវវស្សា. ជួបការលំបាកចែកចាយទឹក, ត្រូវការជីកប្រឡាយចែកចាយ | | | | | |
| | | | | | | |
| រដូវកាល (តាមរដូវឬជាអចិន្ត្រៃយ៍) | | | | | | |
| ការទំនាក់ទំនង (ជាមួយប្រភពទឹកផ្សេងទៀត) | | | | | | |
| ជម្លោះសំខាន់ៗលើការប្រើប្រាស់ទឹក | | | | | | |
| បទដ្ឋាននៃការប្រើប្រាស់ទឹក | | | | | | |
| ការប្រើប្រាស់ល្បឿននៃការនេសាទ | គឺត្រូវរៀបចំការងារទាំងនេះនៅក្នុងឃុំព្រោះការនេសាទសកម្មភាពចិញ្ចឹមយ៉ាងសំខាន់ | | | | | |
| ពូជត្រីសំខាន់ៗ | គឺត្រូវរៀបចំការងារទាំងនេះនៅក្នុងឃុំព្រោះការនេសាទសកម្មភាពចិញ្ចឹមយ៉ាងសំខាន់ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ទំនាក់ទំនងនឹងបរិស្ថាននិង ហានិភ័យ | | | | | | |
| ការបង្កាត់ពូជ ចំណីឬទីជំរក | | | | | | |
| ការប្រើប្រាស់ប្រភពទឹកដោយ បុរស់និងស្ត្រី | | | | | | |
| ប្រើប្រាស់ប្រភពទឹកដោយ បុរស | មិនមានយេឌើរួមបញ្ចូលគ្នា | | | | | |

## ២.៥.ប្រវត្តិសាវតា

បទពិសោធន៍ការវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំបច្ចុប្បន្នបានបង្ហាញថា ការផ្លាស់ប្តូរសំខាន់ៗនៅក្នុងស្ថានភាពអន្តរកាលលើវិស័យកសិកម្មនៅកម្ពុជា ពីការផលិតសម្រាប់ហូបទៅការផលិតសំរាប់ទីផ្សារអាចកំណត់បានដោយការប្រៀបធៀបស្ថានភាពមុននិងក្រោយឆ្នាំ ២០០៧ ។ ប្រវត្តិសាវតានឹងត្រូវបានធ្វើការពិចារណាយ៉ាងសាមញ្ញនៅក្នុងកំឡុងពេលពបីសំខាន់ៗគឺ មុនឆ្នាំ២០០៧ ក្រោយឆ្នាំ២០០៧ និងពេលអនាគត ព្រមទាំងឧបករណ៍ថ្មីមួយត្រូវបានកែសំរួលយ៉ាងងាយស្រួលសំរាប់ធ្វើការវិភាគដូចបង្ហាញនៅក្នុងតារាងខាងក្រោម។បន្ទាប់ពីវិភាគបញ្ចប់លើប្រវត្តិសាវតា សមាជិកក្រុមវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំគួរតែជជែកជាមួយអ្នកផ្តល់ព័តមានសំខាន់ៗនិងរៀបចំតារាងបញ្ហាសំខាន់ៗចំនួនប្រាំដែលបានរកឃើញ។

### ការកែសម្រួលឧបករណ៍

ដែនកំណត់ថ្មី និងបន្ថែមកូឡោលដេកសម្រាប់ដាក់បញ្ចូលពាណិជ្ជកម្មស្រូវ អង្ករក្នុងតារាងកត់ត្រាសាមញ្ញៗត្រូវបានបង្កើតដូចដែលបានបង្ហាញនៅក្នុងឧទាហរណ៏ខាងក្រោម។

### របៀបកត់ត្រា

តារាងកត់ត្រាថ្មីមួយត្រូវបានបង្កើតឡើងដែលបង្ហាញនៅក្នុងឧទាហរណ៏ខាងក្រោម។

### ឧទាហរណ៍ឯកសារមេរៀនបណ្តុះបណ្តាលថ្មី

ដែនកំណត់ប្រវត្តិសាវតាថ្មីនិងតារាងកត់ត្រា

| ពេលវេលា | មុនឆ្នាំ ២០០៧ | ក្រោយឆ្នាំ ២០០៧ | ទស្សនះអនាគតនិងតំរូវការនាពេលខាងមុខ |
|---|---|---|---|
| ប្រជាសាស្ត្រ | ប្រជាជន, ភូមិ, ជនជាតិភាគតិច, ចំណាត់ថ្នាក់ទ្រព្យធន, មធ្យមភាគអាយុ, សុខភាព, បទល្មើស, ទំនាក់ទំនងសង្គម ។ល។ | | |
| កិច្ចការរដ្ឋបាល | អភិបាលកិច្ច, ភ្នាក់ងាររាជរដ្ឋាភិបាល, អាជ្ញាធរដែនដី, គំរោងនានា ។ល។ | | |
| ការប្រស្រ័យទាក់ទង | ផ្លូវថ្នល់, សេវាកម្ម, ការដឹកជញ្ជូន, ថាមពលអគ្គីសនី, ប្រព័ន្ធទូរស័ព្ទ,ប្រព័ន្ធផ្សព្វផ្សាយ , ។ល។ | | |
| ប្រភពព័តមាន | ពីកសិករទៅកសិករ, ក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ, ពាណិជ្ជករ, អ្នកលក់ធាតុចូលកសិកម្ម, ប្រព័ន្ធផ្សព្វផ្សាយ , ។ល។ | | |
| ការងារនៅតាមមូលដ្ឋាន | ប្រភេទ, ទីកន្លែង, វិស័យ/ផ្នែក, មានជំនាញ ឬមិនមានជំនាញ ។ល។ | | |
| ពលករចំណាកស្រុក | ភាគរយក្នុងក្រុមគ្រួសារ, អាយុ, ភេទ, ចំណាត់ថ្នាក់ទ្រព្យធន, មូលដ្ឋាន/តំបន់, ភ្នំពេញ, ក្រៅប្រទេស, វិស័យ/ផ្នែក, មានជំនាញ ឬមិនមានជំនាញ ។ល។ | | |
| អាកាសធាតុ | ទឹកភ្លៀង, សីតុណ្ហភាព, ខ្យល់ព្យុះ, រដូវកាល, ។ល។ | | |
| ជនសាស្ត្រ | លំហូរស្ទឹង/អូរ, ជំរៅបឹង, កំរិតទឹកក្រោមដី, ។ល។ | | |
| ការប្រើប្រាស់/គំរបដី | ដីសាធារណះ/រដ្ឋ, ដីឯកជន, ដីសម្បទាន, ដីប្រើប្រាស់, ដីមានជំលោះ,ភាគរយអ្នកគ្មានដី, ។ល។ | | |
| បរិស្ថាន | ព្រៃឈើ, ទឹក, ដីសើម, សត្វព្រៃ, គុណភាពដី, គុណភាពទឹក, ការប្រើប្រាស់សារធាតុគីមី, ។ល។ | | |
| សកម្មភាពចិញ្ចឹមជីវិត | ប្រភេទមុខរបរ, ចណាត់ថ្នាក់ទ្រព្យធនខុសៗគ្នា, ប្រភពប្រាក់ចំណូល, ។ល។ | | |
| ដាំដំណាំ | ដាំដំណាំសំខាន់ៗ | | |
| ផលិតកម្មស្រូវ | វិធីសាស្ត្រ, ធាតុចូល, ទិន្នផល, ភាពគ្រប់គ្រាន់, លក់ឬសំរាប់ហូប, សំរាប់ទីផ្សារ, ។ល។ | | |
| ប្រភេទពូជស្រូវ | ឈ្មោះ,ភាគរយផ្ទៃដីដាំដុះសរុប, ពូជទំនើប, ពូជក្នុងស្រុក, ស្រូវក្រអូប, ប្រភពពូជ, ។ល។ | | |
| ការប្រើប្រាស់ជី/ថ្នាំពុលកសិកម្ម | ជីគីមី, ជីកំប៉ុស្ត៍, ថ្នាំសម្លាប់សត្វចង្រៃ, ថ្នាំសម្លាប់ស្មៅចង្រៃ ។ល។ | | |
| ពាណិជ្ជកម្មស្រូវអង្ករ | ភាគរយនៃផលិតផលស្រូវសរុបសម្រាប់ហូប និងភាគរយលក់ក្នុងរដូវកាលនីមួយៗ | | |
| យន្តូបនីយកម្ម | ប្រភេទប្រតិបត្តិការណ៏, គ្រឿងយន្ត, កម្មសិទ្ធិ ឬ ជួល, ។ល។ | | |
| ប្រព័ន្ធស្រោចស្រប់ | ប្រភេទ,ភាគរយផ្ទៃដី, ភាគរយចំនួយគ្រួសារ, រដូវកាល, តំលៃទឹក, សហគមន៏កសិករប្រើប្រាស់ទឹក, ដំណើរការណ៏និងការថែទាំ, ។ល។ | | |
| ការចិញ្ចឹមសត្វ/បសុសត្វ | ប្រភេទ, សារះសំខាន់, ចំនួន, ប្រើប្រាស់, ការចិញ្ចឹមសត្វ, ជំងឺ, ពូជ, ប្រភព, ។ល។ | | |
| ជលផល | ការនេសាទ, ពូជ, មធ្យោបាយ, វិធីសាស្ត្រ, ល្បឿននេសាទ/ទំហំ, ច្បាប់, ។ល។ | | |
| អនុផលព្រៃឈើ (NTFPs) | ផលិតផល, បោះបង់ចោល, ប្រើប្រាស់, លក់, ភាគរយប្រាក់ចំណូល, ។ល។ | | |

## ២.៦.ប្រតិទិនរដូវកាលដាំដុះ

ប្រតិទិនរដូវកាលដាំដុះគឺ ត្រូវបានពង្រឹងបន្ថែម ដើម្បីឆ្លើយតបបានល្អតាមតម្រូវការកម្មវិធីអភិវឌ្ឍន៍ផ្នែកពាណិជ្ជកម្មស្រូវដែលធន់នឹងអាកាសធាតុ(Rice-SDP)មើលទៅលើពូជស្រូវក្រអប់ និងបម្រែបម្រួលអា

កាសធាតុ ។ បន្ទាប់ពីការបំពេញចប់តារាងប្រតិទិនរដូវកាលដាំដុះ សមាជិកក្រុមវិភាគប្រព័ន្ធក្សេត្របរិស្ថានឃុំគួរតែពិភាក្សាជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗនិងជ្រើសរើស៥បញ្ហាសំខាន់ជាងគេដែលបានរកឃើញ ។

## ការកែសម្រួលឧបករណ៍

ការកែសម្រួលដើម្បីពង្រឹងបន្ថែមតារាងប្រតិទិនរដូវកាលដាំដុះ ដើម្បីឆ្លើយតបបានល្អតាមតម្រូវការគម្រោងកម្មវិធីជំរុញផលិតកម្មនិងការនាំចេញអង្ករ (Rice-SDP) គឺបញ្ជាក់អក្សរពណ៌ក្រហមក្នុងតារាងឧទាហរហ៍ខាងក្រោម។

## របៀបកត់ត្រា

ប្រើរបៀបកត់ត្រាដូចមុនត្រូវបានកែប្រែដូចបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម ។

## ឧទាហរណ៍ឯកសារមេរៀនបណ្តុះបណ្តាលថ្មី

កែសម្រួលផ្នែកសំខាន់នៃឯកសារមេរៀនបណ្តុះបណ្តាល ដែលទាក់ទងទៅនឹងគំរូនៃការកត់ត្រាលទ្ធផលថ្មីបានបង្ហាញក្នុងឧទាហរណ៍ខាងក្រោម។

គំរូតារាងកត់ត្រាប្រតិទិនរដូវកាលដាំដុះ

| | មករា | កុម្ភៈ | មិនា | មេសា | ឧសភា | មិថុនា | កក្កដា | កញ្ញា | សីហា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| អាកាសធាតុ | | | | | | | | | | | | |
| កំរិតកំពស់ទឹកភ្លៀង | ប្រើដូចឯកសារមុន | | | | | | | | | | | |
| សីតុណ្ហភាព | ប្រើដូចឯកសារមុន | | | | | | | | | | | |
| ទឹកជំនន់ | បង្ហាញពីរយៈពេលនៅពេលជួបទឹកជំនន់ | | | | | | | | | | | |
| រាំងស្ងួត | បង្ហាញពីរយៈពេលនៅពេលជួបរាំងស្ងួត | | | | | | | | | | | |
| ហេតុការណ៍អាកាសធាតុប្រែប្រួលខ្លាំង | បង្ហាញពីរយៈពេលនៅពេលជួបខ្យល់ព្យុះ | | | | | | | | | | | |
| ដំណាំស្រូវ | | | | | | | | | | | | |
| ស្រូវស្រាល | ប្រើបន្ទាត់ពណ៌ខៀវ ចង្អុលប្រាប់ពីសកម្មភាពស្រូវស្រាល | | | | | | | | | | | |
| ស្រូវកណ្តាល | ប្រើបន្ទាត់ពណ៌បៃតង ចង្អុលប្រាប់ពីសកម្មភាពស្រូវកណ្តាល | | | | | | | | | | | |
| ស្រូវធ្ងន់ | ប្រើបន្ទាត់ពណ៌លឿង ចង្អុលប្រាប់ពីសកម្មភាពស្រូវធ្ងន់ | | | | | | | | | | | |
| ស្រូវប្រាំង | ប្រើបន្ទាត់ពណ៌ក្រហម ចង្អុលប្រាប់ពីសកម្មភាពស្រូវប្រាំង | | | | | | | | | | | |
| ស្រូវប្រដេញទឹក | ប្រើបន្ទាត់ពណ៌ខ្មៅ ចង្អុលប្រាប់ពីសកម្មភាពស្រូវប្រដេញទឹក | | | | | | | | | | | |
| ស្រូវចំការ | ប្រើបន្ទាត់ពណ៌ប្រផេះ ចង្អុលប្រាប់ពីសកម្មភាពស្រូវចំការ | | | | | | | | | | | |
| ការរៀបចំដី | ប្រើដូចឯកសារមុន | | | | | | | | | | | |
| ការរៀបចំថ្នាលសំណាប | ប្រើដូចឯកសារមុន | | | | | | | | | | | |
| បាចដី | ប្រើដូចឯកសារមុន | | | | | | | | | | | |
| ស្ទូង | ប្រើដូចឯកសារមុន | | | | | | | | | | | |
| បោចស្មៅ | ប្រើដូចឯកសារមុន | | | | | | | | | | | |
| ច្រូតកាត់ និងបច្ចេកទេសក្រោយប្រមូលផល | ប្រើដូចឯកសារមុនប៉ុន្តែរាប់បញ្ចូលទាំងការគ្រប់គ្រងជញ្ជាំង | | | | | | | | | | | |

| | |
|---|---|
| ដំណាំចំការ | |
| ដំណាំបន្លែ | ប្រើដូចឯកសារមុន |
| ឈើហូបផ្លែ | ប្រើដូចឯកសារមុន |
| កៅស៊ូ | ប្រើដូចឯកសារមុន |
| ចិញ្ចឹមសត្វ | |
| គោ | ប្រើដូចឯកសារមុន |
| ជ្រូក | ប្រើដូចឯកសារមុន |
| មាន់/ទា | ប្រើដូចឯកសារមុន |
| សេដ្ឋកិច្ចសង្គម | |
| ពេលវេលានៃការលក់ | បន្ថែមពេលវេលាលក់ផលិតផលសំខាន់ៗ |
| ថ្លៃ/kg | ប្រើដូចឯកសារមុន |
| តម្លៃពលកម្មខ្ពស់បំផុត | ប្រើដូចឯកសារមុន |

## ២.៧.ការវិភាគនៃផលប៉ះពាល់ប្រែប្រួលអាកាសធាតុ

ការវិភាគនៃផលប៉ះពាល់ប្រែប្រួលអាកាសធាតុ គឺជាឧបករណ៍ថ្មីមួយដែលបានដាក់បញ្ចូលក្នុងការកំណត់បំរែបំរួលអាកាសធាតុឲ្យបានកាន់តែប្រសើ ។ បន្ទាប់ពីបានបញ្ចប់នូវការវិភាគប្រែប្រួលអាកាសធាតុ សមាជិកក្រុមវិភាគប្រព័ន្ធកេ្សត្របរិស្ថានឃុំ គួរតែពិភាក្សាជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ និងជ្រើសរើស៥បញ្ហាសំខាន់ជាងគេដែលបានរកឃើញ ។

### របៀបកត់ត្រា

ព័ត៌មានដែលទទួលបានពីការវិភាគផលប៉ះពាល់ប្រែប្រួលអាកាសធាតុគួរតែបញ្ចូលទៅក្នុងទំរង់នៃការកត់ត្រាដែលបានបញ្ហាញនៅក្នុងឧទាហរណ៍ដូចខាងក្រោម ។

### ឧទាហរណ៍ឯកសារមេរៀនបណ្តុះបណ្តាលថ្មី

ឯកសារមេរៀនបណ្តុះបណ្តាលគួរតែរៀបចំដូចបង្ហាញក្នុងឧទាហរណ៍ខាងក្រោម ។

ទំរង់នៃការកត់ត្រាការវិភាគផលប៉ះពាល់ប្រែប្រួលអាកាសធាតុ

| ប្រភេទប៉ះពាល់ | ពេលវេលា | មានញឹកញាប់ទេ,រយះពេលវែងទេ,ទំហំធំទេ | តំបន់កេ្សត្របរិស្ថានដែលប៉ះពាល់ | ផលប៉ះពាល់ | ការទទួលខុសត្រូវនៅក្នុងតំបន់ |
|---|---|---|---|---|---|
| ការកើនឡើងកំដៅ | ខែណាខ្លះដែលកំដៅនិងសីតុណ្ហភាពកើនឡើង | រលកធាតុអាកាសនិងរយះពេលកំដៅវែង | តើតំបន់មួយណាដែលប៉ះពាល់ច្រើនជាងគេ (លេខរៀងពី១........ដល់....) | តើអ្វីដែលប៉ះពាល់ច្រើនជាងគេ | តើមនុស្សបន្សាំយ៉ាងដូចម្តេចទៅនឹងការប៉ះពាល់ទាំងនោះ |
| ទឹកជំនន់ | ខែណាខ្លះដែលទឹកជំនន់កើនមានឡើង | រយះពេលនឹងភាពញឹកញាប់នៃទឹកជំនន់ | តើតំបន់មួយណាដែលប៉ះពាល់ច្រើនជាងគេ (លេខរៀងពី១........ដល់....) | តើអ្វីដែលប៉ះពាល់ច្រើនជាងគេ | តើមនុស្សបន្សាំយ៉ាងដូចម្តេចទៅនឹងការប៉ះពាល់ទាំងនោះ |

| | | | | | |
|---|---|---|---|---|---|
| ភាពរាំងស្ងួត | ខែណាខ្លះដែលភាពរាំងស្ងួតកើនមានឡើង | រយៈពេលនឹងភាពញឹកញាប់នៃភាពរាំងស្ងួត | តើតំបន់មួយណាដែលប៉ះពាល់ច្រើនជាងគេ (លេខរៀងពី១.......ដល់....) | តើអ្វីដែលប៉ះពាល់ច្រើនជាងគេ | តើមនុស្សបន្សាំយ៉ាងដូចម្តេចទៅនឹងការប៉ះពាល់ទាំងនោះ |
| ភ្លៀងធ្លាក់មិនតាមរដូវកាល | តើភ្លៀងធ្លាក់មិនតាមរដូវកាលកើនមានឡើងនៅក្នុងខែណាខ្លះ | រយៈពេលនឹងភាពញឹកញាប់នៃភ្លៀងធ្លាក់មិនតាមរដូវកាល | តើតំបន់មួយណាដែលប៉ះពាល់ច្រើនជាងគេ (លេខរៀងពី១.......ដល់.....) | តើអ្វីដែលប៉ះពាល់ច្រើនជាងគេ | តើមនុស្សបន្សាំយ៉ាងដូចម្តេចទៅនឹងការប៉ះពាល់ទាំងនោះ |
| ព្រឹត្តិការណ៍ធ្ងន់ធ្ងរ(ខ្យល់ព្យុះ) | តើព្រឹត្តិការណ៍ធ្ងន់ធ្ងរ(ខ្យល់ព្យុះ)កើនមានឡើងនៅក្នុងខែណាខ្លះ | រយៈពេលនឹងភាពញឹកញាប់នៃភ្លៀងធ្លាក់មិនតាមរដូវកាល | តើតំបន់មួយណាដែលប៉ះពាល់ច្រើនជាងគេ (លេខរៀងពី១.......ដល់.....) | តើអ្វីដែលប៉ះពាល់ច្រើនជាងគេ | តើមនុស្សបន្សាំយ៉ាងដូចម្តេចទៅនឹងការប៉ះពាល់ទាំងនោះ |
